# «ដប់ប្រាំបួន-ប៉ែតសិបបួន»

និពន្ធដោយលោកបណ្ឌិត ហ្គាហ្សារ ពាងម៉េត
ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨

**លោក មហាត្មះ គន្ធី**

*មេដឹកនាំនយោបាយឥណ្ឌា ១៨៦៩-១៩៤៨*

**«អ្នកអាចដាក់ច្រវាក់ខ្ញុំ អ្នកអាចធ្វើទារុណកម្មខ្ញុំ**
**អ្នកអាចទាំងបំផ្លាញរូបកាយខ្ញុំទៀត**
**ក៏ប៉ុន្តែអ្នកនៅតែមិនអាចដាក់គុកខួរក្បាលខ្ញុំបានឡើយ»** ។

*សៀវភៅជាភាសាខ្មែរក្រោមចំណងជើងថា «ស្ថានការណ៍នយោបាយនៅកម្ពុជា "ការពង្រឹងនីតិរដ្ឋនិងដំណើរការលិទ្ធិប្រជាធិបតេយ្យ" » និងឯកសារជាភាសាអង់គ្លេស* «CAMBODIA Stability and Development First» *ដែលរបបគ្រប់គ្រងភ្នំពេញបានចេញផ្សាយនៅក្នុងខែកុម្ភៈនេះ បានទាញអារម្មណ៍របស់ខ្ញុំឆ្ពោះទៅប្រលោមលោក* ***Nineteen Eighty-Four*** *ឬ «ដប់ប្រាំបួន-ប៉ែតសិបបួន» ដែលបាននិពន្ធឡើងដោយអ្នករិះគន់ជាតិអង់គ្លេសម្នាក់ឈ្មោះលោក ហ្សក អ័រវែល* George Orwell (១៩០៣-១៩៥០) *ដែលមានឈ្មោះដើមជា អេរិក អាធ័រ ប្លែរ* Eric Arthur Blair *។ លោកកើតនៅរដ្ឋបឹងហ្គាល់ ប្រទេសឥណ្ឌានៅក្នុងសម័យចក្រភពអង់គ្លេសជាអាណានិគមក្នុងគ្រាដែលឪពុករបស់លោកនៅធ្វើជាមន្ត្រីថ្នាក់ទាបម្នាក់នៃសេវាកម្មស៊ីវិលអង់គ្លេស ។ ឪពុកម្ដាយរបស់កុមារ អេរិក ជាអ្នកមិនសូវមានទ្រព្យសម្បត្តិទេ តែ អេរិក មានសំណាងបានទៅរៀននៅសាកលវិទ្យាល័យ អ៊ីតុន* Eton *នៅប្រទេសអង់គ្លេស ។ ពោលគឺនៅស្ថាប័នសិក្សានោះហើយដែល អេរិក អាធ័រ ប្លែរ បានក្រេបជញ្ជក់ឧត្ដមគតិនិងគោលការណ៍សេរីនិយមនិងសង្គមនិយមដែលបានបង្កើតជាទស្សនៈនយោបាយរបស់ហ្សក អ័រវែល ។*

នៅឆ្នាំ ១៩២២ ហ្សក អ័រវែល បានធ្វើការជានគរបាលអធិរាជឥណ្ឌានៅប្រទេសភូមា តែបានលាលែងឈប់ពីតំណែងប្រាំឆ្នាំក្រោយមកព្រោះលោកមិនចូលចិត្តនឹងចក្រពត្តិនិយមអង់គ្លេស ។ នៅឆ្នាំ១៩៣៦ លោកបានទៅប្រទេសអេស្ប៉ាញ ហើយលោកមើលឃើញថាជាប្រទេសសង្គមនិយមពិតប្រាកដមែន ។ លោកក៏ចូលរួមក្នុងការតស៊ូប្រឆាំងនឹងគណៈបក្សហ្វាស៊ីស តែនៅមិនបានយូរ លោកក៏រត់ចេញដោយសារមានការចោទប្រកាន់ថាពួកអ្នកតស៊ូគឺជាពួកបំរើហ្វាស៊ីសទៅវិញ ។ ក្នុងឆ្នាំ ១៩៤១ លោកបានចូលធ្វើការនៅសាជីវកម្មផ្សាយរបស់អង់គ្លេសមួយឈ្មោះ British Broadcasting Company តែដោយមិនសប្បាយចិត្តនឹងកិច្ចការដែលគេតម្រូវឱ្យលោកធ្វើការផ្សព្វផ្សាយឃោសនាទៅកាន់អាណានិគមអង់គ្លេស លោកក៏លាឈប់ពីតំណែងពីរឆ្នាំក្រោយមក ។ នៅក្នុងសង្គ្រាមលោកលោកទី២ (១៩៣៩-១៩៤៥) អ័រវែល បានគាំទ្រលោក វិនស្តុន ឆឺដឈៀល នៅក្នុងសង្គ្រាមប្រឆាំងហ៊ីតល្ហែរ ហើយបានសុំចូលបំរើក្នុងជួរកងទ័ព តែគេមិនទទួលគាត់ដោយសារសុខភាពរបស់គាត់មិនគ្រប់គ្រាន់ ។

លោក ហ្សក អ័រវែល ត្រូវបានគេទទួលស្គាល់ថាជាអ្នកប្រឆាំងនឹងរបបផ្តាច់ការ អ្នកគាំទ្រយ៉ាងម៉ឺងម៉ាត់នូវលទ្ធិសង្គមនិយមប្រជាធិបតេយ្យ អ្នកយល់ដឹងច្បាស់អំពីភាពអយុត្តិធម៌ក្នុងសង្គម និងជាអ្នកសរសេរអក្សរសាស្ត្ររិះគន់បែបកំណាព្យ រឿងប្រឌិត និងសង្គ្រាមប៉ាកកា ។ លោកត្រូវបានគេទទួលស្គាល់យ៉ាងល្បីល្បាញក្នុងលោកដោយសារលោកបាននិពន្ធរូបាទិដ្ឋាន ឬសេចក្តីអធិប្បាយដោយប្រៀបធៀប allegory ប្រលោមលោកមួយក្រោមចំណងជើងថា «កសិដ្ឋានសត្វលោក» Animal Farm ដែលជារឿងប្រលោមលោកច្នៃប្រឌិតឆ្លុះបញ្ចាំងអំពីព្រឹត្តិការណ៍ដែលនាំទៅដល់មានការបដិវត្តន៍រុស្ស៊ីឆ្នាំ១៩១៧ហើយដែលកែប្រែសហភាពសូវៀតពីសង្គមកសិករទៅជាអំណាចឧស្សាហកម្មនិងយោធានៅក្រោមការដឹកនាំលោកស្តាលីន មេដឹកនាំផ្តាច់ការដែលប្រើភេរវកម្មក្នុងការគ្រប់គ្រងអំណាចដែលបណ្តាលឱ្យពលរដ្ឋរាប់លាននាក់ស្លាប់ ។ លោក អ័រវែល បានជឿជាក់ថា សហភាពភាពសូវៀតបាន

ក្លាយទៅជារបបផ្ដាច់ការដ៏សាហាវឃោរឃៅក៏មកពីការកសាងការគោរពបុគ្គលភាព cult of personality និងអំពើភេរវកម្មនានាក្នុងការគ្រប់គ្រង ។ លោកបានសារភាពថា ប្រលោមលោក «កសិដ្ឋានសត្វលោក» ជារឿងទិទានដៀលត្មះដល់មេផ្ដាច់ការ ស្តាលីន ដែលលោកប្រឆាំង -- អាកប្បកិរិយាបែបនេះបានដុះចេញពីបទពិសោធន៍របស់លោកក្នុងអំឡុងសង្គ្រាមស៊ីវិលនៅប្រទេសអេស្ប៉ាញ ។ គេបានបោះពុម្ពផ្សាយ «កសិដ្ឋានសត្វលោក» ក្នុងឆ្នាំ១៩៤៥ ហើយប្រលោមលោកដដែលនេះត្រូវបានសរសេរចងក្រងឡើងនៅចន្លោះឆ្នាំ១៩៤៣និង១៩៤៤ នៅពេលចក្រភពអង់គ្លេសស្ថិតនៅក្នុងសម្ព័ន្ធភាពសម័យសង្គ្រាមជាមួយសហភាពសូវៀត ហើយប្រជារាស្ត្រនិងបញ្ញវន្តអង់គ្លេសទទួលស្គាល់លោកស្តាលីនក្នុងភាពថ្លៃថ្នូរដែលលោកអ័រវែលស្អប់ខ្ពើមជាទីបំផុត ។
សៀវភៅប្រលោមលោកមួយទៀតឈ្មោះថា «***Nineteen Eighty-Four***» ឬ «ដប់ប្រាំបួន-ប៉ែតសិបបួន» ដែលគេនិយមហៅជាលេខ ***1984*** ត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ១៩៤៩ ហើយសព្វថ្ងៃនេះបាននៅជាប់លេខរៀងជាសៀវភៅដែលលក់ដាច់ជាងគេនៅក្នុងពិភពលោក ។

ប្រធានរឿងផងទាំងឡាយដែលលោក អ័រវែល បានលើកមកសរសេរជាង៧០ឆ្នាំមកហើយ (ព្រមទាំងការព្រួយបារម្ភរបស់លោកអំពីអនាគតរបស់ពិភពលោក ) ត្រូវបានគេមើលឃើញថាវាបានកើតមានដូចលោកថាមែនហើយវានៅតែមានជាបន្តរហូតដល់បច្ចុប្បន្នកាលនេះ ។

លោក អ័រវែល បានថ្លែងថា នៅក្នុងការសរសេររបស់លោក លោក «ស្វែងរកការពិត» ។ គេបានសង្កេតឃើញថា ចាប់តាំងពី អ័រវែល ចាប់ផ្ដើមសរសេរនៅអាយុ ២៤ ឆ្នាំមក លោកតែងតែប្រាថ្នាសរសេរបង្ហាញការពិតនៃការតស៊ូរបស់មនុស្ស ហើយលោកស្វែងរកអត្តរសក្នុងចំណោមមនុស្សដែលមានសំណាងតិចតួច ដើម្បីសរសេររឿងរ៉ាវទាំងឡាយរបស់គេ ។ លោក អ័រវែល បានអះអាងថា លោកសរសេរពីព្រោះវាមានការភូតកុហកច្រើនណាស់ដែលលោកត្រូវតែបង្ហាញការពិត ។ គេបានសង្កេតឃើញក្នុងប្រលោមលោក ***1984*** ពោរពេញ

ទៅដោយគោលបំណងនយោបាយ អត្ថន័យ និងការស្តីព្រមាន ។ គេបានសង្កេតឃើញថា សូម្បីតែនៅក្នុងការសរសេរប្រឌិតរបស់លោក ក៏លោកបានបញ្ចេញជាតុពិតនៃពិភពនៅជុំវិញខ្លួនលោកអំពីសង្គ្រាមនិងការតស៊ូដែលលោកបានឃើញផ្ទាល់ភ្នែក អំពីធម្មជាតិនយោបាយគួរឱ្យភ័យខ្លាច និងអំពីភាពគួរឱ្យស្ញែងខ្លាចនៃរបបផ្តាច់ការដែលជិះជាន់ញាំញីលើស្មារតីរបស់មនុស្សលោក ។

ប្រលោមលោក ***1984*** ជារឿងប្រឌិតអំពីកន្លែង dystopia (កន្លែងដែលខ្វះសីលធម៌និងពោរពេញទៅដោយការប្រើអំណាចផ្តាច់ការកៀបសង្កត់ ) មួយនៅតំបន់ អូសេអានី នៅក្នុងអតីតចក្រភពអង់គ្លេស ។ នៅកន្លែងនោះ ពលរដ្ឋរស់នៅជាជនរងគ្រោះនៃសង្គ្រាមអចិន្ត្រៃយ៍ នៅក្រោមការឃ្លាំមើលរបស់របបគ្រប់គ្រងនៅគ្រប់ទីកន្លែង និងជាកន្លែងពោរពេញទៅដោយការអនុវត្តន៍ឧបាយកលបោកបញ្ឆោតសាធារណៈ ។ នៅតំបន់ អូសេអានី មានតែ «គណៈបក្សក្នុង» ទេដែលមានឯកសិទ្ធិ ហើយមាន «ប៉ូលីសគតិ» ដែលមានភារៈដាក់ទោសមនុស្សពីបទ «បុគ្គលនិយម» និង «គំនិតឯករាជ្យ» មិនចុះសម្រុង ដែលរបបចាត់ទុកថាជា «បទឧក្រិដ្ឋគតិ» ។

ការកៀបសង្កត់នេះត្រូវបានគ្រប់គ្រងឡើងដោយអ្នកដឹកនាំដ៏អាថ៌កំបាំងនិងដ៏ខ្លាំងក្លាម្នាក់ ដែលគេហៅថា «បងធំ» Big Brother ។ នៅអូសេអានី គណៈបក្សចាប់អារម្មណ៍តែទៅលើអំណាចរបស់បក្ស និង «ស្វែងរកអំណាចសម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួនទាំងស្រុង» ។

តួឯកនៃប្រលោមលោក ***1984*** គឺលោក វីនស្តុន ស្ម៊ីសត៍ Winston Smith ដែលនៅក្រៅសេវៀនគណៈបក្ស តែជាបុគ្គលម្នាក់ធ្វើការឱ្យ «ក្រសួងសច្ចៈ» Ministry of Truth (Minitrue) នៃរបបគ្រប់គ្រង ទទួលខុសត្រូវក្នុងការឃោសនានិងការកែប្រែប្រវត្តិសាស្ត្រជាថ្មីឡើងវិញ ។ មុខងាររបស់ ស្ម៊ីសត៍ គឺសរសេរឡើងជាថ្មីវិញនូវអត្ថបទចាស់ៗដែលមានបានផ្សាយនៅក្នុងកាសែត ដើម្បីកែប្រែកំណត់ត្រាប្រវត្តិសាស្ត្រឱ្យគាំទ្ររបៀបវារៈនិងនយោបាយរបស់គណៈបក្សក្នុងជាដរាប ។ របបគ្រប់គ្រងបានប្រាប់បុគ្គលិកធ្វើការទាំងអស់ថា ខ្លួនកំពុង

បំពេញភារៈកិច្ចសំខាន់ណាស់ កែតម្រូវកំណត់ដែលបានចុះផ្សាយឥតត្រឹមត្រូវ តែតាមការពិតបុគ្គលិកទាំងនោះកំពុងតែសរសេរព័ត៌មានក្លែងក្លាយជំនួសករណីពិត ហើយក្រសួង Minitrue បានបំផ្លាញចោលនូវការងារកែសម្រួលពីមុនផងទៀតដើម្បីបំបាត់កស្តុតាងនៃការជ្រៀតជ្រែករបស់រដ្ឋាភិបាល ។

លោក វីនស្តុន ស្មីសត៍ ជាមនុស្សឧស្សាហ៍ហើយធ្វើការងារពូកែទៀត ។ ស្មីសត៍ ដែលបានឃើញអំពើកខ្វក់របស់បក្សក៏ចាប់ផ្តើមលួចស្អប់បក្ស ព្រមទាំងលួចស្រមៃគិតគូររកផ្លូវធ្វើការប្រឆាំងនឹង «បងធំ» ។ ស្មីសត៍ បានមើលឃើញភារៈកិច្ច «ក្រសួងសច្ចៈ» គឺ «ត្រួតពិនិត្យការពិត» reality control ។ ស្មីសត៍ លេបមិនចូលសោះនូវបញ្ហាពីបក្សឱ្យពលរដ្ឋបដិសេធទោះបើជាបានមើលឃើញនឹងភ្នែកឬស្តាប់ឮនឹងត្រចៀកនូវភាពមិនល្អរបស់បក្សក៏ដោយពីព្រោះ «បងធំ» មានវត្តមាននៅគ្រប់ទីកន្លែង ហើយគណៈបក្សមិនចេះភាន់ច្រឡំទេ ។ ស្មីសត៍ប្រកាន់ជំនឿថា មាន «ការពិត» នៅក្នុងលោកនេះ គឺថា ដុំថ្មវារឹង ភ្លៀងវាទទឹក ហើយសេរីភាពមានន័យថា លោកអាចនិយាយបានដោយសេរីថា ២+២=៤ ទោះបីបក្សតម្រូវឱ្យថា ២+២=៥ ក៏ដោយ ។

ស្មីសត៍ ក៏ចាប់ផ្តើមធ្វើសកម្មភាពលួចប្រឆាំង ចាប់ពីរក្សាទំនាក់ទំនងផ្លូវភេទ សិចស៊ុយអែលជាមួយនាង ជូលីយ៉ា ដែលធ្វើការនៅនាយកដ្ឋានប្រឌិតរឿងរបស់ក្រសួងសច្ចៈ ។ អ្នកទាំងពីរនាក់ជួលបន្ទប់សំណាក់មួយពីលោក ឆារិនតុន ជាម្ចាស់ហាង ។

នៅថ្ងៃមួយ ស្មីសត៍ បានទទួលសៀវភៅមួយក្បាលពីសមាជិកម្នាក់នៃគណៈបក្សក្នុង ឈ្មោះ អូប្រាយ័ន ដែលបានបង្កប់ខ្លួននៅក្នុងក្រុមខ្វែងមតិ ។ អូប្រាយ័ន បានបញ្ជាក់ប្រាប់ ស្មីសត៍ យ៉ាងលំអិតអំពីភាពកខ្វក់របស់គណៈបក្សក្នុង ល្មមឱ្យស្មីសត៍ទុកចិត្តអូប្រាយ័នទាំងស្រុង រហូតដល់ថ្ងៃដែលអូប្រាយ័នចេញមុខចាប់ខ្លួន ស្មីសត៍ និង នាង ជូលីយ៉ា យកទៅដាក់គុក ។ ក្រោយមក ស្មីសត៍ បានដឹងថា អូប្រាយ័ន និង ឆារិនតុន ជាភ្នាក់ងារ «ប៉ូលិសគតិ» ដែលផ្តន្ទាទោសអ្នកប្រព្រឹត្ត «បទឧក្រិដ្ឋគតិ » ។

ស្មីសត៍ ត្រូវបានទទួលទារុណកម្មជាច្រើនប្រភេទ មានការឃុំឃាំងនៅក្នុងបន្ទប់មួយហៅថា បន្ទប់១០១ ដែលបានធ្វើឱ្យគាត់ភ័យរន្ធត់ព្រោះគាត់ភ័យខ្លាចសត្វកណ្ដុរនៅក្នុងបន្ទប់នោះ ។ ស្មីសត៍ ត្រូវបានគេបង្ខំឱ្យសារភាពទទួលកំហុសផងទាំងឡាយ ។ នៅក្នុងពេលឃុំឃាំងនោះ គេបានប្រើវិធីលាងសំអាតខួរក្បាល ស្មីសត៍ ។

យូរក្រោយមក ស្មីសត៍ និង នាង ជូលីយ៉ា ត្រូវបានគេដោះលែងពីគុកឃុំឃាំងរបស់ «ក្រសួងស្នេហា» Ministry of Love (Miniluv) ឱ្យត្រឡប់ទៅរស់នៅក្នុងសង្គមវិញ។ នៅពេលអ្នកទាំងពីរបានជួបគ្នាឡើងវិញ នាង ជូលីយ៉ា បានប្រាប់ ស្មីសត៍ ថា នាងក៏ត្រូវបានទទួលទារុណកម្មផ្សេងៗដែរ ។
អ្នកនិពន្ធប្រលោមលោក លោក ហ្វ័ច អ័រវែល បានបញ្ចប់រឿងរ៉ាវលោក វិនស្តុន ស្មីសត៍ ដោយបង្ហាញ ស្មីសត៍ កំពុងអង្គុយមើលការបង្ហាញអំពី «បច្ចុប្បន្នភាពយោធា» ដែលបានបញ្ចាំងនៅលើកញ្ចក់អេឡិចត្រូណិច តេលេស្ក្រីន ហើយ ស្មីសត៍ ហាក់ដូចជាមានអារម្មណ៍ លួចសរសើរ «បងធំ » ដែរ -- ដែលអាចជាលទ្ធផលនៃទារុណកម្មនិងការលាងសំអាតខួរ ។

រឿងប្រលោមលោក «***Nineteen Eighty-Four***» ឬ «ដប់ប្រាំបួន-ប៉ែតសិបបួន» ស្ដី អំពីជីវិតស្ថិតនៅក្រោមអំណាចផ្ដាច់ការត្រូវបានសាកលវិទ្យាល័យអាមេរិកាំងនានាតម្រូវឱ្យនិស្សិតថ្នាក់ទីមួយអានក្នុងកម្មវិធីសិក្សា ។ ទាំងនៅក្នុងនិងទាំងនៅក្រៅថ្នាក់រៀន យើងអាចសង្កេតឃើញមានការប្រើគុណនាម Orwellian នៅពេលនិយាយអំពីឥរិយាបថនិងគោលនយោបាយដែលគ្រប់គ្រងដោយការប្រើភាសាថ្មី ការឃោសនា ការលួចឃ្លាំមើល ការផ្ដល់ព័ត៌មានបោកបញ្ឆោត ការបដិសេធការពិត ការកែប្រែប្រវត្តិសាស្ត្រ ការគ្រប់គ្រងគំនិតនិងបញ្ចុះបញ្ចូលគំនិតថ្មី ការអនុវត្តន៍អំណាចផ្ដាច់ការ ។ ពាក្យគន្លឹះនិងគំនិតជាច្រើនចេញពីប្រលោមលោក ***1984*** ត្រូវបានគេយកមកប្រើនៅសព្វថ្ងៃនេះ ដូចជាពាក្យ «បងធំ» (Big Brother) «គំនិតទ្វេរដង» (doublethink -- ស្អប់ខ្ពើមរបបនៅក្នុងគំនិត តែគោរពកោតខ្លាចជាសាធារណៈ) «បទឧក្រិដ្ឋគតិ» (thoughtcrime) «ប៉ូលីសគតិ» (thought police) ។ល។ និង ។ល។

ប្រធានរឿងផងទាំងឡាយដែលលោក អ័រវែល បានសរសេរជាង៧០ឆ្នាំមកហើយ (ព្រមទាំងការព្រួយបារម្ភរបស់លោកចំពោះអនាគតពិភពលោកដែលលោកបានគិតថានឹងមិនអាចគេចផុតពីឆ្នាំ១៩៨៤កន្លងទៅនេះ) ត្រូវបានគេសង្កេតឃើញថា វាបានកើតមានដូចលោកបានទស្សន៍ទាយមែន តែវានៅបន្តមានរហូតបច្ចុប្បន្នកាល ហើយមិនមែនត្រឹមតែនៅក្នុងតំបន់ អូសេអានី ក្នុងរឿងលោក អ័រវែល បានប្រឌិតនោះទេ តែនៅជុំវិញពិភពលោកយើងសព្វថ្ងៃនេះ ។ អ្នកតស៊ូមតិនៅស្ទើរគ្រប់ប្រទេសបានយកប្រលោមលោក ***1984*** មកអានដោយមានការស្ញប់ស្ញែងនឹងសមត្ថភាពមើលឃើញវែងឆ្ងាយរបស់ លោក អ័រវែល ។

គួរកត់សំគាល់ដែរថា បន្ទាប់ពីលោក ដូណាល់ ត្រុមព៍ (កើតនៅឆ្នាំ១៩៤៦ នៅទីក្រុងញ៉ូយ៉ក) បានជាប់ឆ្នោតផ្នែក electoral college ឡើងជាប្រធានាធិបតីអាមេរិកាំងទី ៤៥ នៅឆ្នាំ ២០១៧ មក ប្រលោមលោក ***1984*** ត្រូវបានលក់ដាច់ជាងគេនៅសហរដ្ឋអាមេរិក ។

ក្រុមខ្មែរអ្នកតស៊ូមតិខាងវិស័យលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្សគួរគប្បីយកប្រលោមលោក «***Nineteen Eighty-Four***» ឬ ***1984*** មកអាននិងធ្វើការសញ្ជឹងគិតផងដែរ ។

**លោក ម៉ាទិន លូធើរ ឃីង Martin Luther King, Jr.**

*មេដឹកនាំចលនាតស៊ូសិទ្ធិមនុស្សជាតិអាមេរិកាំង (១៩២៩-១៩៦៨)*

**«ការកែប្រែផ្លាស់ប្តូរមិនមែនចៀសមិនផុតហើយរមៀលចូលដូចតាមកង់រទេះនោះទេ**
**គឺវាកើតចេញមកពីការតស៊ូដែលឥតឈប់ឈរ ។**
**ដូច្នេះចូរយើងពង្រឹងឆ្អឹងខ្នងយើងឱ្យបានត្រង់ឡើង**
**ហើយធ្វើសកម្មភាពដើម្បីសេរីភាពរបស់យើង ។**
**គ្មានជនណាម្នាក់អាចជិះលើខ្នងយើងបានទេលុះត្រាណាតែខ្នងយើងវាពត់កោង » ។**

**អំពីអ្នកនិពន្ធ៖** *លោកបណ្ឌិត ហ្គាហ្វារ ពាងម៉េត អតីតយុទ្ធជនកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ (ឆ្នាំ ១៩៨០-១៩៨៩) បានបង្រៀនវិទ្យាសាស្រ្តនយោបាយចំនួន១៣ឆ្នាំនៅសាកលវិទ្យាល័យកោះ* Guam *(ឆ្នាំ១៩៩១-២០០៤) ។ លោកបានចូលនិវត្តន៍ក្នុងឆ្នាំ២០០៤ ហើយបច្ចុប្បន្ននេះរស់នៅក្នុងសហរដ្ឋអាមេរិក។ លោកអ្នកអាចទាក់ទងនឹងលោកបានតាមរយៈសារអេឡិចត្រូណិច* (e-mail) peangmeth@gmail.com